**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

# បទបញ្ជាផ្ទៃក្នុងគំរូសម្រាប់ មុខរបរឥណទានសហគមន៍កសិកម្ម

រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

គាំទ្រដោយ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

**ខែកញ្ញា ឆ្នាំ២០១៥**

**បទបញ្ញាផ្ទៃក្នុងគំរូសម្រាប់មុខរបរឥណទានសហគមន៍កសិកម្ម**

បោះពុម្ពផ្សាយ៖ ខែកញ្ញា ឆ្នាំ២០១៥

បោះពុម្ពផ្សាយដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អាសយដ្ឋាន៖ លេខៈ៥៤ បេអេហ្វ៤៩/ ផ្លូវ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក

រាជធានីភ្នំពេញ ទូរស័ព្ទលេខ (០២៣) ៨៨៣ ៤២៧ ទូរសារលេខ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា

**ជំពូកទី១ ៖ បទប្បញ្ញត្តិទូទៅ** (ប្រការ១-ប្រការ២)..........................................................**០១**

**ជំពូកទី២ ៖ ប្រាក់កម្ចី** (ប្រការ៣-ប្រការ១០)..........................................................**០១-០៣**

**ជំពូកទី៣ ៖ ប្រាក់បញ្ញើសន្សំធម្មតា និង ប្រាក់បញ្ញើសន្សំមានកាលកំណត់**

(ប្រការ១១-ប្រការ១៤)..........................................................................................**០៣**

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១**

គោលបំណងនៃបទបញ្ជាផ្ទៃក្នុងសម្រាប់មុខរបរឥណទានសហគមន៍កសិកម្ម……………………… គឺដើម្បីកំណត់បែបបទ ចំនួនប្រាក់កម្ចី និងអត្រាការប្រាក់។ សមាជិកសហគមន៍កសិកម្ម……………… និងអ្នកមិនមែនជាសមាជិកសហគមន៍កសិកម្ម…………………… ត្រូវប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនេះ ដោយអនុលោមតាមមាត្រា៣៧ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

**ប្រការ២**

សហគមន៍កសិកម្ម............................... ដែលប្រកបមុខរបរឥណទាន ត្រូវគោរពតាមច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទបញ្ជាផ្ទៃក្នុងនេះ។

# ជំពូកទី ២
## ប្រាក់កម្ចី

**ប្រការ៣**

អ្នកខ្ចីប្រាក់ពីសហគមន៍កសិកម្ម……………………………………………………….. ត្រូវប្រើប្រាស់ប្រាក់កម្ចី សម្រាប់ប្រកបមុខរបរផលិតកម្មកសិកម្ម អាជីវកម្មកសិកម្ម និងមុខរបរដទៃទៀត សំដៅលើកកម្ពស់ កម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

**ប្រការ៤**

ប្រាក់កម្ចីរបស់សហគមន៍កសិកម្ម.......................................................... គឺផ្តល់ជាសាច់ប្រាក់ និងត្រូវមានវិក័យបត្រខ្ចីប្រាក់។

**ប្រការ៥**

អត្រាការប្រាក់លើប្រាក់កម្ចីរបស់សហគមន៍កសិកម្ម............................ ត្រូវកំណត់ដូចខាងក្រោម៖

ក-សម្រាប់សមាជិកសហគមន៍កសិកម្ម...........................................

-ពី១ខែ ដល់ ៦ខែ អត្រាការប្រាក់...........................%ក្នុង១ខែ

-លើសពី៦ខែ ដល់ ១២ខែ អត្រាការប្រាក់................%ក្នុង១ខែ

-លើសពី១២ខែ អត្រាការប្រាក់..............................%ក្នុង១ខែ

ខ-សម្រាប់អ្នកមិនមែនជាសមាជិកសហគមន៍កសិកម្ម..........................

-ពី១ខែ ដល់ ៦ខែ អត្រាការប្រាក់............................%ក្នុង១ខែ

-លើសពី៦ខែ ដល់ ១២ខែ អត្រាការប្រាក់.................%ក្នុង១ខែ

-លើសពី១២ខែ អត្រាការប្រាក់..............................%ក្នុង១ខែ

**ប្រការ៦**

ចំនួនប្រាក់កម្ចីអតិបរមាដែលសហគមន៍កសិកម្ម.................................................អាចផ្តល់ឲ្យអ្នកខ្ចី ត្រូវបានកំណត់ដូចខាងក្រោម៖

១-សម្រាប់សមាជិកសហគមន៍កសិកម្ម៖ ......................................................... រៀល

២-សម្រាប់អ្នកមិនមែនជាសមាជិកសហគមន៍កសិកម្ម៖ ..................................... រៀល

**ប្រការ៧**

ក្នុងករណីហួសកាលកំណត់ ដែលត្រូវសងប្រាក់មកសហគមន៍កសិកម្ម..............................វិញ អ្នកខ្ចីប្រាក់ត្រូវទទួលការពិន័យដោយបង់ការប្រាក់ដូចខាងក្រោម៖

១- ហួសថ្ងៃកំណត់សងប្រាក់រយៈពេល១ខែ៖ ត្រូវពិន័យ.....................................% បន្ថែមលើ អត្រាការប្រាក់ដើម ដូចដែលបានរៀបរាប់ក្នុងប្រការ៥

២-ហួសថ្ងៃកំណត់សងប្រាក់រយៈពេល២ខែ៖ ត្រូវពិន័យ...........................% បូកអត្រាការប្រាក់ពិន័យក្នុងករណីហួសថ្ងៃកំណត់សងប្រាក់រយៈពេល១ខែ បន្ថែមលើអត្រាការប្រាក់ដើម ដូចដែល បានរៀបរាប់ក្នុងប្រការ៥

៣- ហួសថ្ងៃកំណត់សងប្រាក់រយៈពេល៣ខែ៖ ត្រូវពិន័យ..........................% បូកអត្រាការប្រាក់ពិន័យក្នុងករណីហួសថ្ងៃកំណត់សងប្រាក់រយៈពេល១ខែនិងរយៈពេល២ខែ បន្ថែមលើអត្រាការប្រាក់ដើម ដូចដែលបានរៀបរាប់ក្នុងប្រការ៥។ សម្រាប់ខែបន្តបន្ទាប់ទៀត ត្រូវពិន័យដូចក្នុងករណីហួសថ្ងៃកំណត់សងប្រាក់រយៈពេល៣ខែ។

**ប្រការ៨**

ក្នុងករណីអ្នកខ្ចីប្រាក់ ជួបគ្រោះដោយប្រធានសក្តិ (រួមមានដូចជាជួបគ្រោះធម្មជាតិ……………...) សហគមន៍កសិកម្ម...................................... អាចពិចារណាឱ្យអ្នកខ្ចីប្រាក់នោះពន្យារពេលសងប្រាក់កម្ចីដោយមិនគិតពីការពិន័យ ដូចមានចែងក្នុងប្រការ៧។

**ប្រការ៩**

១-ក្នុងករណីដែលសមាជិកសហគមន៍កសិកម្ម………………………………… ខ្ចីប្រាក់តិចជាង ឬស្មើនឹង.......................ដងនៃតម្លៃភាគហ៊ុនសរុប ដែលសមាជិកនោះបានទិញពីសហគមន៍កសិកម្ម .................................. នោះមិនត្រូវឱ្យមានវត្ថុបញ្ចាំទេ ។

២-ក្នុងករណីដែលសមាជិកសហគមន៍កសិកម្ម…………………………………………………..

ខ្ចីប្រាក់ច្រើនជាង................ ដងនៃតម្លៃភាគហ៊ុនសរុបដែលសមាជិកនោះបានទិញពីសហគមន៍កសិកម្ម..................................នោះអ្នកខ្ចីប្រាក់ត្រូវមានក្រុមធានា ដែលមានសមាជិកយ៉ាងតិច ៥នាក់ជាសមាជិកសហគមន៍កសិកម្ម……………………………………… ដោយរាប់បញ្ចូលទាំងអ្នកខ្ចីផងដែរ ឬត្រូវមានវត្ថុបញ្ចាំ ដែលមានតម្លៃយ៉ាងតិចតាមការគណនាក្នុងរូបមន្តដូចខាងក្រោម៖

តម្លៃវត្ថុបញ្ចាំ = [( ចំនួនប្រាក់កម្ចី ) - (................ x តម្លៃភាគហ៊ុនសរុប )] x .............

**ប្រការ១០**

ក្នុងករណីដែលអ្នកខ្ចីប្រាក់ មិនមែនជាសមាជិកសហគមន៍កសិកម្ម...................................ត្រូវកំណត់ឱ្យមានវត្ថុបញ្ចាំ ដែលមានតម្លៃយ៉ាងតិចតាមការគណនាក្នុងរូបមន្តដូចខាងក្រោមៈ

តម្លៃវត្ថុបញ្ចាំ = ចំនួនប្រាក់កម្ចី x .............

## ជំពូកទី ៣

## ប្រាក់បញ្ញើសន្សំធម្មតា និង ប្រាក់បញ្ញើសន្សំមានកាលកំណត់

**ប្រការ១១**

ប្រភេទនៃការសន្សំប្រាក់ និងអត្រាការប្រាក់របស់សហគមន៍កសិកម្ម.............................ត្រូវបាន កំណត់ដូចខាងក្រោមៈ

១-ប្រាក់បញ្ញើសន្សំធម្មតា

- អត្រាការប្រាក់សន្សំធម្មតាគឺ...................................................% ក្នុង១ខែ

២-ប្រាក់បញ្ញើសន្សំមានកាលកំណត់

- អត្រាការប្រាក់បញ្ញើសន្សំមានកាលកំណត់រយៈពេល៦ខែគឺ............% ក្នុង១ខែ
- អត្រាការប្រាក់បញ្ញើសន្សំមានកាលកំណត់រយៈពេល១ឆ្នាំគឺ............% ក្នុង១ខែ
- អត្រាការប្រាក់បញ្ញើសន្សំមានកាលកំណត់រយៈពេល២ឆ្នាំគឺ............% ក្នុង១ខែ

**ប្រការ១២**

អ្នកដាក់ប្រាក់បញ្ញើជាមួយសហគមន៍កសិកម្ម...........................អាចដកប្រាក់បញ្ញើសន្សំធម្មតាវិញបានគ្រប់ពេលវេលា ប៉ុន្តែអ្នកដាក់ប្រាក់បញ្ញើនោះ ត្រូវជូនដំណឹងមកសហគមន៍កសិកម្ម .................. ឱ្យបានមុន.............ថ្ងៃ។

**ប្រការ១៣**

អ្នកដាក់ប្រាក់បញ្ញើជាមួយសហគមន៍កសិកម្ម...............................អាចដកប្រាក់បញ្ញើសន្សំមានកាលកំណត់មុនពេលកំណត់ ប៉ុន្តែអ្នកដាក់ប្រាក់បញ្ញើនោះ ត្រូវជូនដំណឹងមកសហគមន៍កសិកម្ម……….. ................ឱ្យបានមុន.............ថ្ងៃ។ ក្នុងករណីនេះ អ្នកដាក់ប្រាក់បញ្ញើនោះ អាចទទួលបានការប្រាក់ចំនួន............% ក្នុង១ខែ ។

**ប្រការ១៤**

សហគមន៍កសិកម្ម..........................ត្រូវរក្សាទុកថវិកាចំនួន.............% នៃប្រាក់បញ្ញើសន្សំធម្មតា និងថវិកាចំនួន.................% នៃប្រាក់បញ្ញើសន្សំមានកាលកំណត់ នៅក្នុងធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ សម្រាប់ពេលដែលអ្នកដាក់ប្រាក់បញ្ញើជាមួយសហគមន៍កសិកម្ម............................. សុំដកប្រាក់។

**Internal Regulation for Credit Business of Agricultural Cooperative**

Printed in September 2015

Published by Department of Agricultural Cooperative Promotion of GDA (MAFF)

The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,

Phone: (023) 883 427, Fax : 023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models